# ព្រះរាជក្រម

នស/រកម/០១១៩/១៩

## យើង

## ព្រះបាទសម្ដេច ព្រះនរោត្ដម សីហមុនី រាជហរិវង្ស

## ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្ដម

## ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

## ព្រះចៅក្រុងកម្ពុជាធិបតី

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងនាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី២
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្ដីពីការកែសម្រួលសមាសភាពនៃរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្ដីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- តាមសេចក្ដីក្រាបបង្គំទូលស្នើសុំអំពីសម្ដេចនាយករដ្ឋមន្ត្រីទាំងពីរ

# ប្រកាសឲ្យប្រើ

ច្បាប់ស្ដីពីការបង្កើតក្រសួងធម្មការ និងសាសនា ដែលរដ្ឋសភាបានអនុម័តនាសម័យ ប្រជុំលើកទី៥ នីតិកាលទី១ ដែលមានសេចក្ដីទាំងស្រុងដូចតទៅៈ

សហការរៀបចំដោយអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល និងកម្មវិធីកំណែទម្រង់រដ្ឋបាល និងវិមជ្ឈការ (GIZ)-ចម្លងខ្លឹមសារទាំងស្រុងតាមច្បាប់ដើម

# ច្បាប់
# ស្តីពី
# ការបង្កើតក្រសួងធម្មការ និងសាសនា

**មាត្រា ១** : ត្រូវបានបង្កើតក្រសួងធម្មការ និងសាសនា ចំណុះរាជរដ្ឋាភិបាលកម្ពុជា។

**មាត្រា ២** : ក្រសួងធម្មការ និងសាសនា មានសមត្ថកិច្ចដឹកនាំ និងគ្រប់គ្រងលើវិស័យធម្មការ និងសាសនា នៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៣** : ក្រសួងធម្មការ និងសាសនា ត្រូវបានដឹកនាំដោយរដ្ឋមន្ត្រីមួយរូប ឬរដ្ឋលេខាធិការមួយរូប ដែលអាចអមដោយអនុរដ្ឋលេខាធិការ តាមការចាំបាច់។

**មាត្រា ៤** : ការរៀបចំរចនាសម្ព័ន្ធ និងការប្រព្រឹត្តទៅរបស់ក្រសួងធម្មការ និងសាសនា ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា ៥** : បទប្បញ្ញត្តិទាំងឡាយដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៦** : ច្បាប់នេះត្រូវប្រកាសជាប្រញាប់។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦

**ព្រះហស្តលេខា**

**នរោត្តម សីហនុ**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រីទី ១** **នាយករដ្ឋមន្ត្រីទី ២**

**នរោត្តម រណឫទ្ធិ** **ហ៊ុន សែន**